អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## លោក JUSTICE STEVEN J. BWANA
## ត្រូវបានតែងតាំងជាចៅក្រមបម្រុងអន្តរជាតិនៅអង្គបុរេជំនុំជម្រះ

ដោយអនុលោមតាមការជ្រើសតាំងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន និង ដោយមានការបោះឆ្នោតសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ នរោត្តម សីហមុនី បានតែងតាំងលោក Justice Steven J. Bwana (មកពីប្រទេសតង់ហ្សានី) ជាចៅក្រមបម្រុងអន្តរជាតិថ្មី នៅអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ជំនួសលោកស្រីចៅក្រម Kathinka Lahuis (មកពីប្រទេសហុល្លង់)។

លោក Justice Bwana ដែលបច្ចុប្បន្នក៏ជាចៅក្រមនៅតុលាការសាលាឧទ្ធរណ៍នៃប្រទេសតង់ហ្សានី មានបទពិសោធន៍ការងារចំនួនជាង៣៨ឆ្នាំ ក្នុងនាមជាចៅក្រម ជាមន្ត្រីអគ្រានុកូលដ្ឋាន ជាអ្នកជំនាញច្បាប់ក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។ លោកមានសញ្ញាប័ត្របណ្ឌិតនិងអនុបណ្ឌិតច្បាប់មកពីសាកលវិទ្យាល័យ Lateran នៅទីក្រុង រ៉ូម និងសញ្ញាប័ត្រអនុបណ្ឌិតនិងបរិញ្ញាប័ត្រច្បាប់មកពីសាកលវិទ្យាល័យ Dar es Salaam។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៨៥(0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh